# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*ផ្អែកតាមទំនាក់ទំនង ដែលខ្ញុំជិតស្និតជាមួយ **នួន ជា***
*គាត់គឺជាមនុស្សសុភាពរាបសារ ជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ និងផ្តល់ដំបូន្មានល្អៗ។*
*តាមការសង្កេតរបស់ខ្ញុំ គាត់បានអប់រំប្រជាជនឲ្យក្លាយជាមនុស្សល្អ។*

សាក្សី **អឿន តាន**

## I. ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានបន្តស្តាប់សាក្សី **សៅ សារុណ** និងសាក្សី **ឃឹម ងន** ។ សាក្សី **សៅ សារុណ** គឺជាលេខាស្រុក ក្រោយមកក្លាយជាលេខាតំបន់១០៥[1]។ ចំណែកឯ សាក្សី **ឃឹម ងន** ក្រោយឆ្នាំ ១៩៧៥[2] បានធ្វើការនៅក្រសួងការបរទេស។ អង្គជំនុំជម្រះក៏បានស្តាប់សក្ខីកម្មសាក្សីថ្មីម្នាក់ទៀត គឺលោក **អឿន តាន**[3] គាត់គឺជាបុគ្គលដែលធ្វើការជាមួយ **ប៉ុល ពត** ក្នុងនាមជានីរសារ និងកងការពារ។ សាក្សីទាំង ៣រូប ត្រូវបានបញ្ចប់សក្ខីកម្មនៅក្នុងសប្តាហ៍នេះ។

តាមបទពិសោធន៍របស់សាក្សី **សៅ សារុណ** គាត់បានផ្តល់ព័ត៌មាន អំពីគោលនយោបាយបក្ស និងរចនាសម្ព័ន្ធថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចំពោះសក្ខីកម្មរបស់សាក្សី **ឃឹម ងន** គាត់បានផ្តោតសំខាន់អំពីភារកិច្ចរបស់គាត់នៅក្រសួងការបរទេស (រចនាសម្ព័ន្ធរបស់ថ្នាក់ដឹកនាំ និងការចាប់ខ្លួននៅ ក្រសួងការបរទេស)។ ចំណែកឯសាក្សី **អឿន តាន** ដោយសារតែបានធ្វើការជាមួយ **ប៉ុល ពត** ជាង ៩ឆ្នាំ ដូច្នេះ គាត់អាចផ្តល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងថ្នាក់ដឹកនាំខ្មែរក្រហម និងប្រព័ន្ធទំនាក់ទំនងរវាង **ប៉ុល ពត** និងមេដឹកនាំនានា។

## II. **សេចក្ដីសង្ខេបនៃសក្ខីកម្មសាក្សី**

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានព្យាយាមជជីកដេញដោលសាក្សី **សៅ សារុណ** ដោយស្វែងរកព័ត៌មានទាក់ទងនឹងការអនុវត្តន៍នៃគោលការណ៍បក្សនៅតំបន់ ១០៥។ សក្ខីកម្មរបស់សាក្សី **សៅ សារុណ** ក៏បានបង្ហាញពីរចនា សម្ព័ន្ធរដ្ឋបាលនៅថ្នាក់តំបន់ និងប្រព័ន្ធទំនាក់ទំនងជាមួយថ្នាក់ដឹកនាំ។ សាក្សីទី២ **ឃឹម ងន** គាត់បានរៀបរាប់អំពីតួនាទីខ្លួន ក្នុងនាមជាអ្នកអមដំណើរភ្ញៀវបរទេសនៃក្រសួងការបរទេស ទៅធ្វើទស្សនកិច្ចនៅតាមបណ្ដាខេត្ត ស្ថានភាពនៅទីជនបទ និងការបោសសម្អាតនៅក្រសួងការបរទេស។ ជាចុងក្រោយ សាក្សី **អឿន តាន** ដែលធ្លាប់ជានិរសារ និងកងការពាររបស់ **ប៉ុល ពត** បានផ្ដល់សក្ខីកម្ម អំពីការហែរហាមអមដំណើរបងធំទី១ និងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ក្រោយពីការជម្លៀសនៅភ្នំពេញ។

### ក. សក្ខីកម្មរបស់សាក្សី សៅ សារុណ

ការថបថយនៃការចងចាំរបស់សាក្សី បានបណ្ដាលឲ្យសក្ខីកម្មរបស់គាត់ពុំគ្រប់ដណ្ដប់សព្វជ្រុងជ្រោយ។ ភាគីបានប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់សាក្សី ដែលធ្វើនៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំ និងបញ្ជាក់ពីភាពមិនស៊ីសង្វាក់គ្នា។

**១. រចនាសម្ព័ន្ធតំបន់ ១០៥**

សាក្សី **សៅ សារុណ** គឺជាលេខាស្រុក ក្រោយមក គាត់ត្រូវបានតែងតាំងជាលេខាតំបន់១០៥ (ខេត្តមណ្ឌលគីរី) នៅក្នុងមហាសន្និបាតបក្សនៅទីក្រុងភ្នំពេញ កញ្ញា ១៩៧៨[4] ដែលជាដំណែងបន្តពី **តាល័ង្គ** ដែលជាមេកើយខ្លួន។ សាក្សីបានឲ្យដឹងថា តំបន់១០៥ គឺមានបួនមន្ទីរ ៖ មន្ទីរ ក-១១[5] មន្ទីរ ក-១៦ មន្ទីរ ក-១៧[6] និងមន្ទីរពាណិជ្ជកម្ម។ មន្ទីរ ក-១៧ និងមន្ទីរ ក-១១ មានទីតាំងនៅភ្នំក្រោល[7] ចំណែកឯមន្ទីរ ១០៥ គឺជា "ការិយាល័យរួម" ចំពោះលេខកូដ ១០៥ គឺបញ្ជាក់ពីខេត្តមណ្ឌលគីរី។ សាក្សីពុំបានដឹងពីការគ្រប់គ្រងទេ ព្រោះនាពេលនោះ **តាល័ង្គ** គឺជាលេខាតំបន់ ចំណែករូបគាត់ទទួលបន្ទុកត្រឹមតែថ្នាក់ស្រុក។ នៅពេលចៅក្រម **ហ្សង់ម៉ាក់ ឡាវែន៍** សួរសំណួរពាក់ព័ន្ធនឹងបុគ្គលឈ្មោះ **ម៉ី** ឈ្មោះ **ចាម** ឈ្មោះ **ផាក** ឈ្មោះ **លក**? សាក្សីបានឲ្យដឹងថា គាត់បានស្គាល់ពួកគេ ប៉ុន្តែពុំមានភាពជិតស្និត និងពុំបានដឹងពីមូលហេតុនៃការបាត់ខ្លួនរបស់ពួកគេទេ។[8]

ជាងនេះទៀត សាក្សីបានបញ្ជាក់ថា គណៈតំបន់មានសមាជិកយ៉ាងតិចចំនួន ៣រូប ដែលក្នុងនោះមានឈ្មោះ **សុភា** ម្នាក់ដែរ។ **សុភា** បានក្លាយជាប្រធានមន្ទីរសន្តិសុខភ្នំក្រោល បន្ទាប់ពី **តាល័ង្គ**[9] ត្រូវបានសម្លាប់។ នាពេលនោះ គាត់ពុំបានដឹងថាមានមន្ទីរសន្តិសុខភ្នំក្រោលទេ ព្រោះគាត់មានឋានៈត្រឹមតែថ្នាក់ស្រុក។ មន្ទីរតំបន់ និងមន្ទីរសន្តិសុខភ្នំក្រោល គឺជាមន្ទីរពីរផ្សេងគ្នា។ "មន្ទីរសន្តិសុខភ្នំក្រោល" មានលក្ខណៈស្រដៀងនឹង "មន្ទីរកែប្រែ"។ ឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី **ទី ស្រីណា** សាក្សីបានបន្ថែមថា ក៏មានមន្ទីរ "យោធាមជ្ឈិម" ឬហៅថា មន្ទីរ ៩២០ ដែលមន្ទីរនេះមានទីតាំងនៅស្រុករបស់គាត់។ សាក្សីបានពន្យល់ថា៖

*តាមការយល់ដឹងរបស់ខ្ញុំ យោធាគណៈមជ្ឈិម គឺមានការយល់ដឹងពីទីតាំងភូមិសាស្ត្រច្រើន ជាងយោធាថ្នាក់តំបន់ គឺពួកគេស្គាល់តែទឹកដីភូមិសាស្ត្រខ្លួនប៉ុណ្ណោះ។*

**២. ប្រព័ន្ធទំនាក់ទំនង**

ផ្អែកតាមសាក្សី បន្ទាប់ពីលេខាតំបន់ **តាល័ង្គ** បានស្លាប់បាត់បង់ជីវិត **ប៉ុល ពត** បានណែនាំឲ្យគាត់រាយការណ៍ទៅការិយាល័យ ៨៧០ ឬខ្លួនគាត់ដោយផ្ទាល់ នៅពេលមានប្រជុំ ឬតាមរយៈសារទូរលេខ។ សាក្សីបានផ្ញើសារចំនួន ៣ ច្បាប់ ទៅការិយាល័យ ៨៧០ និង **ប៉ុល ពត** ពាក់ព័ន្ធនឹងការវាយប្រហារនៅឃុំត្រាងតែម។ នៅពេលមានសំណួរពីតំណាងសហព្រះរាជអាជ្ញា **លីសាក់** ពាក់ព័ន្ធនឹងសារទូរលេខចំនួន ៤ច្បាប់ ដែលសាក្សីផ្ញើជូនថ្នាក់ដឹកនាំនៅទីក្រុងភ្នំពេញ ចន្លោះខែមករា-មេសា ១៩៧៨? សាក្សីបានថ្លែងថា សារទូរលេខទាំងនោះ គឺជារបាយការណ៍ប្រចាំខែ ដែលផ្ញើជូន **ប៉ុល ពត**។

សាក្សី **សៅ សារុណ** ក៏បានឲ្យដឹងថា គាត់បានទទួលបញ្ជាពីថ្នាក់លើ (ពីភ្នំពេញ) ពាក់ព័ន្ធនឹងការធ្វើកសិកម្ម ការណែនាំឲ្យប្រជាជនក្លាយជាប្រជាពលរដ្ឋល្អ ការពង្រឹងសេដ្ឋកិច្ច និងការទប់ទល់ការចូលឈ្លានពានរបស់វៀតណាម។ សាក្សីធ្លាប់បានទទួលសារទូរលេខពី **នួន ជា** ដែលកោះអញ្ជើញគាត់ឲ្យចូលរួមវគ្គអប់រំ និងសារទូរលេខពី **ប៉ុល ពត** ដែលបានណែនាំគាត់ឲ្យចូលរួមកិច្ចប្រជុំនៅទីក្រុងភ្នំពេញ។ នៅពេលមានសំណួរពាក់ព័ន្ធនឹងលិខិតដែលសាក្សី **សៅ សារុណ** បានផ្ញើជូនទៅ **ខៀវ សំផន** ស្នើសុំសម្ភារៈ ឬការផ្គត់ផ្គង់នានា សាក្សីបានបញ្ជាក់ថា គាត់បានជួបប្រាស្រ័យជាមួយ **ខៀវ សំផន** តិចតួចប៉ុណ្ណោះ អំពីផលិតផលស្រូវ។

**៣. ការអនុវត្តន៍គោលការណ៍បក្ស**

សាក្សី **សៅ សារុណ** បានបដិសេធថា គាត់ពុំធ្លាប់ឃើញការបង្ខំឲ្យរៀបការទេ។ ក្នុងនាមជាលេខាតំបន់១០៥ សាក្សីក៏ពុំមានអំណាចចាប់បង្ខំនរណាម្នាក់ឲ្យរៀបការដែរ ការរៀបការគឺត្រូវតែមានការអនុញ្ញាតពីឪពុកម្តាយ ទោះបីជាមាន "សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" ពីររូប គឺ D22/1433 និង D22/1175 បានលើកឡើងថាពួកគេគឺត្រូវបានបង្ខំឲ្យរៀបការ។ សេចក្តីថ្លែងការណ៍មួយបានឲ្យដឹងថា គាត់បានឃើញការបង្ខំឲ្យរៀបការចំនួន ១៨គូ ប្រសិនបើនរណាម្នាក់មិនបានគោរពតាមបញ្ជា ពួកគេនឹងត្រូវចាប់ខ្លួន។ លោកស្រីមេធាវី **ស៊ីម៉ុនណូហ្វូត** បានរំឭកការចងចាំរបស់សាក្សី ដោយអានសេចក្តីថ្លែងការណ៍មួយ សាក្សីនៅតែរក្សាចម្លើយថា គាត់ពុំបានដឹងពីការរៀបការដោយបង្ខំ។

សាក្សីក៏បានបដិសេធថា គាត់ពុំបានឃើញ និងបានដឹងពីការជម្លៀសប្រជាជនដោយបង្ខំទៅតំបន់របស់ខ្លួនទេ ទោះបីជាមានសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានបញ្ជាក់ថា គាត់ត្រូវបានជម្លៀស និងបញ្ជូនទៅខេត្តមណ្ឌលគីរី និងបញ្ជូនបន្តទៅព្រំដែនកម្ពុជា-វៀតណាម។

### ៤. មហាសន្និបាតបក្សឆ្នាំ១៩៧៨

សាក្សីបានផ្តល់សក្ខីកម្មថា គាត់បានចូលរួមមហាសន្និបាតបក្សនៅខែកញ្ញា ១៩៧៨ នៅបូរីកីឡា ទីក្រុងភ្នំពេញ រៀបចំឡើងបន្ទាប់ពីវៀតណាមចូលគៀក។ មហាសន្និបាត គឺជាកិច្ចប្រជុំដែលមានអ្នក តំណាងចូលរួមពីទូទាំងប្រទេស និងសមាជិកកងយោធា អ្នកចូលរួមរាប់រយនាក់ រួមទាំង **ប៉ុល ពត** - **នួន ជា** - **ខៀវ សំផន** - **អៀង សារី** - **អៀង ធីរិទ្ធ** - និង **សុន សេន** ។ មហាសន្និបាតប្រព្រឹត្តទៅមានរយៈពេល ១០ថ្ងៃ។ សាក្សីបានចំណាំ និងស្គាល់ថ្នាក់ដឹកនាំមួយចំនួន ព្រោះនាពេលនោះពួកគេបានអញ្ជើញឡើងទៅលើវេទិកាសម្រាប់អធិបតី។

កំឡុងមហាសន្និបាតឆ្នាំ១៩៧៨ ជនជាប់ចោទ **នួន ជា** បានផ្តល់សុន្ទរកថា អំពី "ការគ្រប់គ្រងប្រជាជន - ការផ្តល់លំនៅដ្ឋាន និងអាហារគ្រប់គ្រាន់ដល់ប្រជាជន" និងលើកពីបញ្ហានានា ដូចជា ការបើកទីផ្សារឡើងវិញ - ការបើកឲ្យមានចរាចរក្រដាសប្រាក់ឡើងវិញ - និងការអនុញ្ញាតឲ្យប្រជាជនត្រឡប់ទៅទីក្រុងភ្នំពេញវិញ។ សាក្សីពុំបានដឹងថា គោលនយោបាយទាំងនេះត្រូវបានអនុវត្ត ព្រោះគាត់បានចាកចេញពីទីក្រុងភ្នំពេញក្រោយពីមហាសន្និបាត។ សាក្សីបន្ថែមថា ចំពោះការកសាងវត្តអារ៉ាមឡើងវិញ ពុំត្រូវបានលើកយកមកពិភាក្សាទេ។

នៅក្នុងមហាសន្និបាត **ប៉ុល ពត** បានថ្លែងថា ការចាប់ចងត្រូវបញ្ចប់ ពុំមាននរណាម្នាក់មានអំណាច ក្នុងការចាប់ចង ឬសម្លាប់មនុស្សដោយគ្មានការអនុញ្ញាតពីគណៈមជ្ឈិម ព្រោះបក្សបានសម្រេចនូវគោលការណ៍សម្រិតសម្រាំងខ្មាំងសត្រូវហើយ។ ជាងនេះទៀត ថ្នាក់ដឹកនាំបានណែនាំឲ្យអ្នកចូលរួមធ្វើការផ្សព្វផ្សាយគោលនយោបាយនេះ ទៅដល់ថ្នាក់តំបន់ និងថ្នាក់ស្រុក និងឲ្យអ្នកចូលរួមចាត់វិធានការដាក់វិន័យទៅដល់បុគ្គលដែលនៅតែចាត់ទុកមនុស្សថាជាសត្រូវ ដូចជា ការចូលរួម **ស៊ី.អាយ.អេ** ឬពួកវៀតកុងជាដើម។ សាក្សីពុំបានដឹងពីដំណើរដើមទង ដែលធ្វើឲ្យបក្សផ្លាស់ប្តូរគោលនយោបាយឡើយ។ សាក្សីបន្តថា នៅពេលគាត់ត្រឡប់មកដល់តំបន់១០៥វិញ គាត់បានរៀបចំកិច្ចប្រជុំធ្វើការផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីមហាសន្និបាត។ តំណាងសហព្រះរាជអាជ្ញា **លីសាក់** បានសួរបញ្ជាក់ថាតើមានការចាប់ខ្លួនដោយចោទប្រកាន់ថាជាជនក្បត់ ឬជាខ្មាំងសត្រូវនៅខេត្តមណ្ឌលគីរី ក្រោយពីមហាសន្និបាត ១៩៧៨? សាក្សីបានឆ្លើយតបថា "គ្មានទេ! ក្រោយខែកញ្ញា ១៩៧៨ គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួនឡើយ"។

នៅក្នុងមហាសន្និបាតនៅទីក្រុងភ្នំពេញ **ប៉ុល ពត** បានឲ្យសាក្សី **សៅ សារុណ** អានចម្លើយសារភាពដែលចោទប្រកាន់លើខ្លួនឯង និងបុគ្គលពីរនាក់ទៀត ប៉ុន្តែសាក្សីបានបដិសេធលើការលើកឡើងនេះ គាត់ពុំបានប្រព្រឹត្តកំហុសអ្វីទេ និងពុំមានហេតុផលដែលនាំឲ្យមានការឆ្លើយទម្លាក់កំហុសលើគាត់ឡើយ។ សាក្សីក៏ពុំបានចងចាំពីចម្លើយសារភាព ដែលឆ្លើយទម្លាក់កំហុសលើគាត់។

### ៥. ការទម្លាក់គ្រាប់បែកដោយអាមេរិកកាំង

សាក្សី **សៅ សារុណ** បានរៀបរាប់ថា គាត់មានបទពិសោធន៍ផ្ទាល់ការទម្លាក់គ្រាប់បែកពីអាមេរិកកាំងពីឆ្នាំ ១៩៧០ - ១៩៧៥។ នាពេលនោះ វត្តអារ៉ាមជាច្រើន រួមទាំងវត្តមួយនៅស្រុកឆឹងមីងក៏ត្រូវបំផ្លាញដែរ។ អាមេរិកកាំងបានប្រើយន្តហោះភ្ជាប់ដោយ បេ-៥២ ទម្លាក់គ្រាប់បែកនៅខេត្តមណ្ឌលគីរី។ គ្រាប់បែកបានបំផ្លិចបំផ្លាញស្រែចំការ ចម្ការដំណាំជាច្រើន និងសមាជិកគ្រួសាររបស់គាត់ចំនួន ១១នាក់ រងរបួសជាទម្ងន់ ចំណែកឯប្រជាជនជាច្រើនទៀតបានស្លាប់បាត់បង់ជីវិត។ ប្រជាជនតិចតួចណាស់ដែលរួចរស់ជីវិតពីការវាយប្រហារដ៏ធ្ងន់ធ្ងរនេះ។ ប្រជាជនបានរត់ភៀសខ្លួនពីភូមិកំណើតទៅរស់នៅក្នុងព្រៃដែលពុំមានកន្លែងស្នាក់អាស្រ័យត្រឹមត្រូវទេ។ សាក្សីពុំបានដឹងពីមូលហេតុពីការទម្លាក់គ្រាប់បែកដោយពួកអាមេរិកកាំងទេ។

### ៦. អត្តចរិក និងភាពគួរជឿជាក់នៃសាក្សី

នៅក្នុងសក្ខីកម្ម សាក្សីមានភាពប្រយ័ត្នប្រយែងក្នុងការឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ក្នុងនាមជាលេខាតំបន់ (រយៈពេល ២ខែ) សាក្សីបានឲ្យដឹងថា គាត់ពុំធ្លាប់បានចាប់ចង ឬបង្ខំឲ្យរៀបការ ឬបង្ខំឲ្យជម្លៀសទេ ទោះបីជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកផ្ទុយពីនេះ។ ការបដិសេធមិនឆ្លើយសំណួរ និងមិនផ្តល់ចម្លើយប្រឆាំងលើខ្លួនឯង សាក្សី **សៅ សារុណ** តែងតែលើកថា ដោយសារបញ្ហាសុខភាពចុះទ្រុឌទ្រោម ដូច្នេះគាត់មិនអាចចងចាំពីព្រឹត្តការណ៍ ពីអតីតកាលទេ។

### ខ. សក្ខីកម្មរបស់សាក្សី ឃឹម ងន

សាក្សី **ឃឹម ងន** គឺជាអតីតយុទ្ធជនមួយរូប ទទួលបន្ទុកជានិរសារនៅខេត្តតាកែវ។ ក្រោយមក គាត់បានប្តូរទៅធ្វើការនៅក្រសួងការបរទេសទៅទីក្រុងភ្នំពេញ ទទួលបន្ទុកជាអ្នកហែរហមភ្ញៀវរបស់ក្រសួងការបរទេស។ សាក្សី **ឃឹម ងន** បានផ្តល់សក្ខីកម្មថា គាត់ពុំបានដឹងពីការជម្លៀសប្រជាជនចេញពីទីរួមខេត្តតាកែវ និងការបោសសម្អាតនៅក្រសួងការបរទេស។ សេចក្តីថ្លែងរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះផ្ទុយពីព័ត៌មាន ដែលគាត់ផ្តល់នៅសហចៅក្រមស៊ើបអង្កេត។

### ១. ខេត្តតាកែវ

សាក្សី **ឃឹម ងន** បានចាប់ផ្តើមសក្ខីកម្មនៅថ្ងៃទី១១ មិថុនា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី **ឡោ ឈុនធី** បានសួរដេញដោលពាក់ព័ន្ធនឹងតួនាទីរបស់គាត់ជាយោធានៅខេត្តតាកែវមុនពេលទទួលជ័យជំនះលើទីក្រុងភ្នំពេញ និងពីអត្ថន័យដែលគាត់បានលើកឡើងកាលពីសប្តាហ៍មុនថា "ការជម្លៀសចេញពីទីរួមខេត្តតាកែវ ***ត្រឡប់ក្រោយ***"។ សាក្សី

**ឃឹម ងន** បានឆ្លើយថា គាត់ពុំបានឃើញការជម្លៀសប្រជាជន ហើយក៏ពុំបានពន្យល់ពីអត្ថន័យនៃពាក្យ "ត្រឡប់ក្រោយ" ដែរ បែរជាលើកឡើងថា ប្រជាជនត្រូវបានចាប់ដាក់ក្នុងរថយន្តរបស់មិត្តភ័ក្រគាត់ម្នាក់ឈ្មោះ **ធឿន**។

### ២. ផ្ទះលេខ៧ នៅក្រសួងការបរទេស

សាក្សីបានផ្តល់សក្ខីកម្មអំពីតួនាទី និងភារកិច្ចរបស់គាត់ នៅពេលមកដល់ផ្ទះលេខ៧ នៅក្រសួងការបរទេស។ តំណាងសហព្រះរាជអាជ្ញា **វ៉ាំងស្យង់ ដឺវាយ** បានចោទសំណួរ ថាតើនរណាជាអ្នកមានឋានៈខ្ពស់ជាងគេនៅក្រសួងការបរទេស និងជាអ្នកអមដំណើរគណៈប្រតិភូបរទេសសាក្សីបានឆ្លើយថា ឈ្មោះ **ហុង** ដែលជាប្រធានមន្ទីរ គឺជាអ្នកអមដំណើរភ្ញៀវការបរទេស។ "តាមរយៈឈ្មោះ **ភឿង** (អនុប្រធានមន្ទីរ) បានឲ្យដឹងថា **ខៀវ សំផន** ក៏ប្រហែលជាអមដំណើរភ្ញៀវការបរទេសផងដែរ"។ ពួកគេបាននាំភ្ញៀវពីទីក្រុងភ្នំពេញទៅតំបន់របស់ខ្លួន (ការធ្វើដំណើរពុំមានឈប់សម្រាកឡើយ) ដូច្នេះ ពួកគេពុំមានឱកាសពិភាក្សាជាមួយភ្ញៀវទេ។ ក្នុងឱកាសមួយ នៅពេលគាត់អមដំណើរភ្ញៀវជនជាតិចិនទៅខេត្តតាកែវ គាត់បានជួបបងប្អូនជីដូនមួយនៅសហករណ៍ ហើយទទួលដំណឹងថា បងជីដូនមួយស្រីម្នាក់ត្រូវបានគេ "សម្លាប់"។

### ៣. ការបោសសម្អាតនៅក្រសួងការបរទេស

តំណាងសហព្រះរាជអាជ្ញា **វ៉ាំងស្យង់** បានចោទសំណួរ ថាតើមាន "ការបោសសម្អាត" នៅក្រសួងការបរទេសឬទេ? ជាការឆ្លើយតប សាក្សីឲ្យដឹងថា គាត់ពុំបានដឹងពីបញ្ហានៃការចាប់ខ្លួនមនុស្សទេ ប៉ុន្តែបានដឹងថា "មានមនុស្សត្រូវបានយកចេញពីកន្លែងមួយទៅកន្លែងមួយ និងមិនឃើញត្រឡប់មកវិញឡើយ"។ ឈ្មោះ **ច្រឿង** ដែលត្រូវជាមិត្តរួមការងារនៅក្រសួងការបរទេស ត្រូវបានផ្លាស់ប្តូរទៅកន្លែងផ្សេង ហើយក្រោយមកពុំបានឮដំណឹងពីគាត់សោះ។ សាក្សីមានមន្ទិលសង្ស័យថា ឈ្មោះ **ហុង** គឺជាអ្នកចេញបញ្ជាឲ្យចាប់ **ច្រឿង** ប៉ុន្តែ ថាតើ **ហុង** ទទួលបញ្ជាបន្តពីថ្នាក់លើ ឬចេញបញ្ជាដោយខ្លួនឯង? គាត់ពុំបានដឹងឡើយ។ នៅពេលមានសំណួរ ថាតើមានអ្វីកើតឡើងចំពោះមនុស្សដែលត្រូវចាត់ទុកថាជាខ្មាំងសត្រូវ ឬជាជនក្បត់? សាក្សី **ឃឹម ងន** ពុំបានឆ្លើយតបទៅនឹងសំណួរឡើយ ប៉ុន្តែបានថ្លែងថា គាត់និងមិត្តរួមការងារ គឺមានការភ័យខ្លាចជាខ្លាំង ក្រោយពីមានការដក **ច្រឿង** ព្រោះពួកគាត់ជឿជាក់ថា ប្រសិនបើមនុស្សម្នាក់ត្រូវបានដកចេញដោយបញ្ហានយោបាយ ជាបន្ទាប់ មនុស្សផ្សេងទៀតនឹងមានជោគវាសនាដូចគ្នា។

នៅពេលមេធាវី **បាណាបេ ណេគ្វី** សួរដេញដោលសាក្សី អំពីមន្ទីរ ប-១[10] សាក្សីបានបដិសេធថា គាត់ពុំបានដឹង ពីការចាប់មនុស្សនៅមន្ទីរ ប-១ ព្រោះគាត់ស្នាក់នៅផ្ទះលេខ៧ ដូច្នេះ គាត់ពុំបានដឹងពីបញ្ហាកើតឡើងនៅកន្លែងផ្សេង ឡើយ។ ជាការរំឭកសាក្សី មេធាវី **បាណាបេ** បានដកស្រង់សេចក្តីថ្លែងការណ៍របស់សាក្សីម្នាក់ដែលលើកឡើងថា ស្ត្រីឈ្មោះ **ធី** បានប្រាប់គាត់អំពីការចាប់ខ្លួនមនុស្សនៅមន្ទីរនានានៅក្រសួងការបរទេស។ ស្ត្រីឈ្មោះ **ធី** ពិតជាបាន

ប្រាប់គាត់អំពីហេតុការណ៍នៃការចាប់ខ្លួនមនុស្សមែន ប៉ុន្តែគាត់ពុំបានចងចាំអំពីព័ត៌មានលម្អិតនៃហេតុការណ៍នោះទេ។ ជាបន្ទាប់ មេធាវី **បាណាបេ** ក៏ពុំបានជជីកសួរដេញដោលបន្តពីបញ្ហានេះដែរ។

### ៤. ការដកមនុស្សទៅតាខ្មៅ

សាក្សី **ឃឹម ងន** បានផ្តល់សក្ខីកម្មថា នៅពេលគាត់ធ្វើការនៅផ្ទះលេខ៧ ឈ្មោះ **អឿង** បានទិតៀនគាត់ពី "ការប្រព្រឹត្តអំពើអសីលធម៌" ព្រោះគាត់ "ជជែកលេង" ជាមួយនារីៗ។ ជាលទ្ធផល សាក្សីត្រូវបានបញ្ជូនទៅ "លត់ដំ" នៅតាខ្មៅរយៈពេល ៣ខែ នៅឆ្នាំ១៩៧៦។ ឈ្មោះ **ហុង** ដែលជាមេរបស់គាត់បានជួយគាត់ឲ្យរួចចេញពីតំបន់នោះ។ នៅតាខ្មៅ គាត់តម្រូវឲ្យដាំបន្លែ និងសរសេរប្រវត្តិរូបរបស់ខ្លួនចំនួន ៣លើក។ នាពេលនោះ មនុស្សជាង ២០នាក់ មកពីមន្ទីរក្រសួងនានា និងទីជនបទ ដោយទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តកំហុស។ តំណាងសហព្រះរាជអាជ្ញា **វ៉ាំងស្សង់** បានចោទសំណួរ ថាតើមនុស្សនៅតាខ្មៅត្រូវបានយកចេញទៅទីណាបន្តទៀត? សាក្សីបានឆ្លើយថា ពុំមាននរណាម្នាក់ត្រូវបានបាត់ខ្លួនទេនាពេលនោះ។ សហព្រះរាជអាជ្ញាបានលើកពីចំណុចមិនស៊ីសង្វាក់នៃសក្ខីកម្មរបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះ និងនៅដំណាក់កាលចៅក្រមស៊ើបអង្កេត ដោយលើកថា "ពួកគេទាំងនោះត្រូវបានបាញ់សម្លាប់ទាំងអស់ លើកលែងតែគាត់ម្នាក់"។ ចំពោះភាពមិនស៊ីសង្វាក់នេះ សាក្សីមិនបានបកស្រាយឡើយ ហើយសហព្រះរាជអាជ្ញាក៏មិនសួរបន្តដែរ។

មេធាវី **ឡោ ឈុនធី** បានសុំឲ្យសាក្សី **ឃឹម ងន** បញ្ជាក់ពីមូលហេតុចំពោះការលត់ដំនៅតាខ្មៅ និងពីមូលហេតុដែលភរិយារបស់បងប្អូនជីដូនមួយត្រូវបានគេ "កម្ទេច"។ សាក្សីពុំបានថ្លែងពីបញ្ហានេះ ហើយពុំបានបដិសេធថា គាត់ត្រូវបានបញ្ជូនទៅតាខ្មៅរយៈពេល ៣ខែ បន្ទាប់ពីទស្សនកិច្ចនៅខេត្តតាកែវ។

### ៥. វត្តមានលោក ហ៊ុន សែន នៅក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហម

នៅពេលមេធាវី **ម៉ៃឃល ផេស្តមិន** (មេធាវីការពារក្តីលោក **នួន ជា**) បានអានអត្ថបទនៃកិច្ចសម្ភាសន៍របស់សាក្សី **ឃឹម ងន** ធ្វើនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានលើកឡើងថា គាត់បានឃើញនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ រួមមាន **សុន សេន** - **អៀង សារី** - **នួន ជា** - និង **ប៉ុល ពត**។ សាក្សីបានបដិសេធមិនទទួលស្គាល់ និងបានថ្លែងថា ៖

> *អត់ទេ! ខ្ញុំមិនគិតថា ខ្ញុំបានឆ្លើយចម្លើយនេះទេ ខ្ញុំមិនដឹងពីបញ្ហានេះឡើយ ខ្ញុំមិនដឹងទេ។ ជឿ ឬមិនជឿ ខ្ញុំមិនបាននិយាយបែបនេះទេ! វាខុសពីបទពិសោធន៍របស់ខ្ញុំ ព្រោះខ្ញុំមិនចេះអាន និងមិនចេះសរសេរ ប្រហែលជានរណាម្នាក់សរសេរជំនួសខ្ញុំ។ ខ្ញុំអត់ដឹងទេ។*

ប្រធានអង្គជំនុំជម្រះ **និល ណុន** បានណែនាំឲ្យមេធាវី **ផេស្តមិន** តាំងសំណួរថ្មី ដោយសារតែសាក្សីបានលើកហើយថា គាត់ពុំបានដឹងពីបញ្ហានេះឡើយ។ ទោះបីជាមានការណែនាំពីប្រធានអង្គជំនុំជម្រះ ក៏មេធាវី **ផេស្តមិន** នៅតែបន្តសួរសាក្សី ថាតើគាត់មានការភ័យខ្លាចចំពោះការផ្តល់សក្ខីកម្មអំពីលោក **ហ៊ុន សែន** ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំខ្មែរក្រហម? ប្រធានអង្គជំនុំជម្រះបានណែនាំសាក្សីមិនឲ្យឆ្លើយតបទៅសំណួរ ព្រោះជាសំណួរដែល "ពុំមានការពាក់ព័ន្ធ"។ មេធាវី **ផេស្តមិន** បានលើកសម្អាងថា សំណួរនេះពិតជាមានការជាប់ពាក់ព័ន្ធ និងអាចស្វែងយល់ពីការពិភាក្សានៅក្នុងកិច្ចប្រជុំ ដែលកូនក្តីរបស់ខ្លួនមានវត្តមាន។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះពុំបានផ្តល់ឱកាសឲ្យមេធាវី **ផេស្តមិន** សួរបន្តទេ។ មេធាវីសម្តែងការមិនពេញចិត្ត និងលើកឡើងថា ៖

*លោកប្រធានអង្គជំនុំជម្រះ! ខ្ញុំមិនយល់ថា ត្រូវបន្តទៅចំណុចផ្សេងឡើយ។ លោកមិនអនុញ្ញាតឲ្យយើងអនុវត្តសិទ្ធិរបស់កូនក្តីចំពោះការសួរដេញដោលសាក្សី ជាពិសេស សួរសំណួរសំខាន់ៗ។ ខ្ញុំមានការសោកស្តាយណាស់!*

### គ. សក្ខីកម្មរបស់សាក្សី អឿន តាន

សាក្សី **អឿន តាន** គឺជានិរសារ និងជាកងការពាររបស់ **ប៉ុល ពត** នៅឆ្នាំ១៩៧០-១៩៧៩។ សាក្សីបានផ្តល់ព័ត៌មានអំពីទំនាក់ទំនង និងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែគាត់មិនអាចផ្តល់ព័ត៌មានលម្អិតនៃខ្លឹមសារនៅក្នុងសារលិខិតដែលគាត់បានបញ្ជូនទេ។

### ១. តួនាទីភារកិច្ចនៅក្នុងចលនាបដិវត្តន៍

សាក្សី **អឿន តាន** បានផ្តល់សក្ខីកម្មថា ឈ្មោះ **គង់ ដែង** (លេខាស្រុកនៅក្នុងខេត្តរតនគីរី) បានណែនាំគាត់ឲ្យចូលរួមចលនាបដិវត្តន៍នៅឆ្នាំ១៩៦៨។ សាក្សី **អឿន តាន** បានរៀបរាប់ថា គាត់គឺជាកសិករ និងជាជនជាតិដើមភាគតិចកាចុក។ គាត់រកឱកាសរៀនសូត្រ (រៀនអាន និងសរសេរ) សាក្សីបានពន្យល់ថា ៖

*ក្នុងនាមជាជនជាតិដើមភាគតិច ខ្ញុំមិនចេះអ្វីទាំងអស់។ ខ្ញុំធ្វើការប្រើកម្លាំងតែម្យ៉ាង។ ដូច្នេះ នៅពេលខ្ញុំទទួលព័ត៌មានពីបដិវត្តន៍ ខ្ញុំមានចំណាប់អារម្មណ៍ ចង់ដឹងពីបដិវត្តន៍ និងខ្ញុំចង់រៀនសូត្រ ព្រោះខ្ញុំគិតថា ការចូលរួមបដិវត្តន៍អាចធ្វើឲ្យខ្ញុំបានសិក្សា។ នាបច្ចុប្បន្ន ជនជាតិដើមភាគតិចអាចអាន និងសរសេរបាន ប្រសិនបើពួកគេទៅសាលា។ នេះគឺជាចម្លើយរបស់ខ្ញុំទៅនឹងសំណួររបស់លោក អំពីមូលហេតុនៃការចូលរួមបដិវត្តន៍ ព្រោះខ្ញុំចង់រៀន ចង់ចេះអាន និងចេះសរសេរ។*

សាក្សី **អឿន តាន** បានឲ្យដឹងថា គាត់ពុំបានទទួលការបណ្តុះបណ្តាល ដូចការរំពឹងទុក! "ខ្ញុំនៅក្នុងព្រៃ ពុំមានសៀវភៅ ពុំមានការសិក្សា។ មនុស្សដែលមានការចំណេះដឹងច្រើន បានជួយបង្រៀនដល់ពួកយើង។ នាពេលនោះ ពួកយើងប្រើធ្យូងសម្រាប់សរសេរ (សរសេរលើបំពងឫស្សី)"។

ផ្អែកតាមសាក្សី ឈ្មោះ **ផៃ** ដែលជាមេកង បានចាត់តាំងសាក្សីឲ្យធ្វើជានិរសារ។ នៅឆ្នាំ ១៩៧០ **ប៉ុល ពត** - **ប៉ង់** - និងសាក្សី បានទៅខេត្តកំពង់ចាម គាត់នៅទីនោះក្នុងឋានៈជានិរសារ។ សាក្សីពុំដឹងពីខ្លឹមសារនៅក្នុងសំបុត្រ និងមិនធ្លាប់បញ្ជូនសំបុត្រទៅ "កងចល័តកុមារ" ប៉ុន្តែគាត់បានឮឈ្មោះពីកងចល័តនេះ ព្រមទាំងមិនធ្លាប់បញ្ជូនសំបុត្រដែលជាប់ពាក់ព័ន្ធនឹងការរៀបការជាមួយជនពិការ។ នៅក្នុងឆ្នាំនោះ **ប៉ង់** បានចាត់តាំងគាត់ឲ្យធ្វើជាកងការពាររបស់ **ប៉ុល ពត** ដោយមានតួនាទីហែរហម **ប៉ុល ពត** ទៅចូលរួមកិច្ចប្រជុំនានានៅថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក រហូតដល់វៀតណាមចូលមកដល់នៅឆ្នាំ ១៩៧៩។

នៅពេលមានសំណួរអំពី "ការរំដោះ" ទីក្រុងភ្នំពេញ សាក្សីបានឲ្យដឹងថា **ប៉ុល ពត** - **នួន ជា** - **ខៀវ សំផន** - និង **ប៉ង់** បានធ្វើដំណើរទៅទីក្រុងភ្នំពេញ ប្រហែលជា ២សប្តាហ៍ ក្រោយពីទីក្រុងត្រូវបានរំដោះ[11]។ សាក្សី **អឿន តាន** បានមកតាមថ្នាក់ដឹកនាំ នៅពាក់កណ្តាលខែឧសភា ១៩៧៥។ ទិដ្ឋភាពនៅតាមដងផ្លូវ មានមនុស្សធ្វើដំណើរជាច្រើនទាំងក្មេងទាំងចាស់។ នៅពេលមកដល់ទីក្រុង គឺមានសភាពស្ងាត់ជ្រងំ និងគ្មានមនុស្សទាល់តែសោះ ព្រោះប្រជាជនចាកចេញអស់ហើយ។ បន្ទាប់មក **ប៉ង់** បានតែងតាំង គាត់ឲ្យធ្វើជាប្រធានកងសន្តិសុខ គ្រប់គ្រងមនុស្សចំនួន ១០នាក់។ សាក្សី **អឿន តាន** ធ្វើការនៅផ្ទះ **ប៉ុល ពត** នៅមន្ទីរ ក-១។ សាក្សី និងកងការពារក្រោមបង្គាប់ បានមើលការការពារសន្តិសុខរបស់ថ្នាក់ដឹកនាំ និងជួយការងារដាំបន្លែ ជួយរៀបចំម្ហូបអាហារ និងបោកគកផងដែរ។

## ២. ទំនាក់ទំនងជាមួយថ្នាក់ដឹកនាំ

សាក្សីបានឲ្យដឹងថា គាត់បានឃើញ **នួន ជា** - **ខៀវ សំផន** - និង **អៀង សារី** ជាលើកដំបូងក្នុងកិច្ចប្រជុំនៅឆ្នាំ ១៩៧០ នាពេលនោះ គាត់បានក្លាយជាកងការពាររបស់ **ប៉ុល ពត** ហើយ។ ថ្នាក់ដឹកនាំបានរៀបចំកិច្ចប្រជុំ ៣ ឬ ៤ដងក្នុងមួយខែ។ ក្នុងនាមជាកងការពារសន្តិសុខ ពួកគាត់ឈរការពារពីចម្ងាយ (ប្រមាណជា ២០ម៉ែត្រ) នៅបរិមាណជុំវិញ ដូច្នេះពុំបានឮពីការសន្ទនារបស់ថ្នាក់ដឹកនាំទេ។ សាក្សីក៏ពុំបានដឹងពីតួនាទីរបស់ **នួន ជា** និង **ខៀវ សំផន** ដែរ ប៉ុន្តែបានថ្លែងថា បងធំទី២ **នួន ជា** គឺជាមនុស្សសុភាពរាបសារ និងមានការអប់រំខ្ពស់ និងផ្តល់ដំបូន្មានល្អៗដល់ពួកគាត់។ សាក្សីបានឮថា **អៀង សារី** គឺទទួលបន្ទុកលើក្រសួងការបរទេស និងស្ថិតក្នុងជួរថ្នាក់ដឹកនាំ។

សាក្សី **អឿន តាន** ផ្តល់សក្ខីកម្មថា **ប៉ុល ពត** - **នួន ជា** - **ខៀវ សំផន** - និង **ប៉ង់** ធ្វើការនៅមន្ទីរ ក-១។ ចំណែក **អៀង សារី** និង **អៀង ធីរិទ្ធ** បានចូលរួមកិច្ចប្រជុំដែលរៀបចំ និងមានអធិបតីភាពរបស់ **ប៉ុល ពត**។ កិច្ចប្រជុំធំៗជាមួយតំណាងថ្នាក់ស្រុក ថ្នាក់តំបន់ និងថ្នាក់ភូមិភាគ គឺត្រូវបានរៀបចំនៅមន្ទីរ ក-១។ សំបុត្រកោះអញ្ជើញធ្វើដោយ **ប៉ង់** ហើយគាត់ត្រូវបញ្ជូនទៅមន្ទីរ ក-៧[12] ដែលជាកន្លែងបញ្ជូនបន្តទៅតំបន់នានា។ លោក **នួន ជា** - **ខៀវ សំផន**

- និង **អៀង សារី** តែងតែបានចូលរួមកិច្ចប្រជុំទាំងនោះ ប៉ុន្តែលោកស្រី **អៀង ធីរិទ្ធ** បានចូលរួមម្តងម្កាល។ ជារៀងរាល់ឆ្នាំជាង ៤ ទៅ ៥ដង **ប៉ុល ពត** បានរៀបចំកិច្ចប្រជុំនៅស្ពាតអូរឡាំពិកនៅទីក្រុងភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណជា ១០០ ទៅ ២០០នាក់ ដែលស្លៀកពាក់ជាទាហាន ហើយ **សុន សេន** តែងតែមានវត្តមានក្នុងកិច្ចប្រជុំនោះមិនដូចថ្នាក់ដឹកនាំដទៃទេ។

### ក. ការងារជាមួយ ប៉ង់

ផ្អែកតាមសាក្សី **អឿន តាន** នៅមន្ទីរ ក-១ ការប្រើប្រាស់សារទូរលេខ គឺក្នុងការទំនាក់ទំនង ហើយ **ប៉ង់** ជាអ្នកទទួលខុសត្រូវលើផ្នែកនេះ។ សាក្សីទទួលសារទូលេខពីនិរសាររបស់ **ប៉ង់** និងបញ្ជូនបន្តទៅ **ប៉ុល ពត** ប្រហែលជា ២ ទៅ៣ដង ក្នុងមួយថ្ងៃ។ នៅពេលមានសំណួរពីតំណាងសហព្រះរាជអាជ្ញា **តារិក អាប់ឌុលឡាក់** ថាតើ **ប៉ុល ពត** ធ្លាប់បញ្ជាគាត់ឲ្យបញ្ជូនសារទៅកន្លែងដទៃទេ? សាក្សីបានឆ្លើយថា “បាទ! ខ្ញុំធ្លាប់បានបញ្ជូនសារទូរលេខទៅ **នួន ជា**”។

នៅមន្ទីរ ក-១ **ប៉ង់** តែងតែរៀបចំការប្រជុំបុគ្គលិក ដែលណែនាំកុំឲ្យពួកគេប្រព្រឹត្តអំពីអសីលធម៌។ សាក្សី **អឿន តាន** បានផ្តល់សក្ខីកម្មថា នៅពេល **ប៉ង់** បាត់ខ្លួន[13] សាក្សីបានព្យាយាមស្វែងរកគាត់ ប៉ុន្តែ ការខិតខំនេះពុំទទួល បានជោគជ័យទេ។ នៅពេល **ប៉ង់** បាត់ខ្លួន សាក្សីមានការភ័យខ្លាចជាខ្លាំងអំពីជោគវាសនារបស់ខ្លួន គឺអាចក្លាយជាអ្នកបាត់ខ្លួនបន្ទាប់ ប៉ុន្តែ “ក្រោយពីការបាត់ខ្លួន **ប៉ង់** នៅមន្ទីរ ក-១ ឬ មន្ទីរដទៃពុំមានការបាត់ខ្លួនទៀតឡើយ”។ ចំពោះចាប់ខ្លួនមនុស្ស គឺដោយចោទប្រកាន់ថា ជាជនក្បត់ ដូចជា ឈ្មោះ **កើត** ឈ្មោះ **ធ័រ** ហៅ **សែម** (ប្រធានមន្ទីរ ក-១)។ នៅពេលសហព្រះរាជអាជ្ញាបង្ហាញសេចក្តីថ្លែងការណ៍របស់សក្សី TCW-620 (សក្សីមិនទាន់ចូលមកផ្តល់សក្ខីកម្ម) សាក្សី **អឿន តាន** បានបដិសេធថា គាត់ពុំធ្លាប់ដកខ្លួនមនុស្សនៅក្រោមបង្គាប់ ដោយសារតែការប្រព្រឹត្តអំពើធ្ងន់ធ្ងរទេ មានតែ **ប៉ង់** ដែលមានអំណាចចាប់ និងបញ្ជូនខ្លួន។

### ខ. សុខភាពរបស់ ប៉ុល ពត

នៅពេលមានសំណួរអំពីលក្ខខណ្ឌសុខភាពរបស់ **ប៉ុល ពត** សាក្សីរៀបរាប់ថា គាត់ពុំធ្លាប់ឃើញ **ប៉ុល ពត** មានជម្ងឺធ្ងន់ធ្ងរទេ ប៉ុន្តែមានពេលខ្លះ **ប៉ុល ពត** មានជម្ងឺតិចតួច ហើយជម្ងឺនោះជាសះស្បើយភ្លាមៗ បន្ទាប់ពីមានការព្យាបាល។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសាកសួរ ថាតើនៅពេលណាសាក្សីបានដឹងថា **ប៉ុល ពត** មានជម្ងឺជាទម្ងន់ និង **នួន ជា** បានឡើងជំនួស? សាក្សីឆ្លើយថា “ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនដឹងអំពីបញ្ហានេះទេ”។

## III. បញ្ហាច្បាប់ និងនិតិវិធី

នាសប្ដាហ៍នេះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់សាក្សី (សាក្សីមិនទាន់មកផ្ដល់សក្ខីកម្ម) ធ្វើជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីដែលកំពុងផ្ដល់សក្ខីកម្ម។ តុលាការក៏បានអនុញ្ញាតឲ្យមេធាវីការពារក្ដីលោក **នួន ជា** ប្រើប្រាស់ឯកសារដែលមានតែជាភាសា អង់គ្លេសនៅក្នុងការសួរដេញដោល។

### ក. ការប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់សាក្សីផ្សេងជាមូលដ្ឋានក្នុងការសួរដេញដោល

នៅថ្ងៃអង្គារ មេធាវី **ហ្សាស្កេ ប៉ៅ** បានសុំការអនុញ្ញាតសួរដេញដោលសាក្សី **សៅ សារុណ** ដោយដាក់បង្ហាញសេចក្ដីថ្លែងការណ៍របស់សាក្សី TCW-307 ដែលជាសាក្សីមិនទាន់មកផ្ដល់សក្ខីកម្ម។ មេធាវី **ប៉ៅ** បានផ្ដល់មូលដ្ឋានថា សេចក្ដីថ្លែងការណ៍នេះ គឺមានការពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី **សៅ សារុណ** ហើយសាក្សី **សៅ សារុណ** ក៏បានទទួលស្គាល់ពីបញ្ហានេះ ហើយក៏អាចជួយដល់តុលាការក្នុងការស្វែងរកការពិត។ លោកមេធាវីបន្តទៀតថា វិធីសាស្ត្រនេះ សហព្រះរាជអាជ្ញាបានប្រើប្រាស់កាលពីសប្ដាហ៍មុន ហើយអាចទាញព័ត៌មាន ដែលមានអត្ថប្រយោជន៍ពី សាក្សី។ លោកមេធាវីបានធានាថា នឹងមិនបញ្ចេញឈ្មោះសាក្សីទេ គឺប្រើតែរហ័សនាមប៉ុណ្ណោះ (“TCW-307”)។ ប្រសិនបើរង់ចាំសាក្សីនេះមកផ្ដល់សក្ខីកម្ម មេធាវីការពារក្ដីនឹងខកខានមិនអាចសួរតទល់ជាមួយសាក្សី **សៅ សារុណ** បានទេ។ សហព្រះរាជអាជ្ញា និង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការជំទាស់ទៅនឹងសំណើនេះ។

អង្គជំនុំជម្រះបានធ្វើវិសោធនកម្មលើសេចក្ដីសម្រេចរបស់ខ្លួន គឺបានអនុញ្ញាតឲ្យមេធាវីការពារក្ដីលោក **នួន ជា** ប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់ TCW-307 ក្នុងការសួរតទល់ជាមួយសាក្សី **សៅ សារុណ**។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមថា ពុំឲ្យបញ្ចេញអត្តសញ្ញាណរបស់សាក្សី គឺឲ្យប្រើតែរហ័សនាម ព្រមទាំងមិនឲ្យដាក់បង្ហាញឯកសារនៅលើកញ្ចក់ទូរទស្សន៍។ មេធាវី **ប៉ៅ** បានថ្លែងថា គាត់នឹងអានតែផ្នែកពាក់ព័ន្ធ និងផ្ដល់ឱកាសដល់ភាគីត្រួតពិនិត្យថាតើគាត់ធ្វើត្រឹមត្រូវ។ អង្គជំនុំជម្រះបានសម្រេចតាមសំណើនេះ។

នៅថ្ងៃពុធ អង្គជំនុំជម្រះក៏បានអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** ប្រើប្រាស់សេចក្ដីថ្លែងការណ៍របស់សាក្សីដែលមិនទាន់មកផ្ដល់សក្ខីកម្មចំពោះការសួរដេញដោលសាក្សី **អឿន តាន** គឺសេចក្ដីថ្លែងការណ៍របស់សាក្សី TCW-620 ហើយអត្តសញ្ញាណរបស់សាក្សីមិនត្រូវបានបញ្ចេញទេ។

### ខ. ការលើកឡើងសក្ខីកម្មដែលផ្ដល់ដោយភាគីដទៃក្នុងការសួរដេញដោលសាក្សី

នៅថ្ងៃអង្គារ ទី១២ មិថុនា មេធាវី **ប៉ៅ** បានប៉ុនប៉ងលើកសារជាថ្មី អំពីសក្ខីកម្មរបស់សាក្សី **សៅ សារុណ** កាលពីថ្ងៃប្រហស្បតិ៍ ទី៧ មិថុនា នៅពេលតំណាងសហព្រះរាជអាជ្ញា **លីសាក់** បានចោទសួរ ថាតើនរណាមានវត្តមាននៅក្នុងកិច្ចប្រជុំ ក្រោយពី **តាល័ង្គ** ស្លាប់។ ផ្អែកតាមសាក្សី គឺមានតែ **ប៉ុល ពត** ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនោះ។ តំណាងសហព្រះរាជអាជ្ញាបានអានសេចក្ដីថ្លែងការណ៍របស់សាក្សីធ្វើនៅតំណាក់កាលសហចៅក្រមស៊ើបអង្កេត ៖ “**ខៀវ សំផន** - **សុន សេន** - និង **នួន ជា** ក៏មាន វត្តមាននៅទីនោះដែរ”។ បន្ទាប់ពីឮដូច្នេះ សាក្សីបានរក្សាចម្លើយរបស់

ខ្លួន ថាពិតជាមានលក្ខណៈត្រឹមត្រូវ[14]។ នៅពេលមេធាវី **ប៉ៅ** បានសួរឡើងវិញពីចំណុចនេះ សហព្រះរាជអាជ្ញាបានធ្វើការជំទាស់ដោយឈរមូលដ្ឋានថា លោកមេធាវីមានការភ័ន្តច្រលំចំពោះសក្ខីកម្មរបស់សាក្សី **សៅ សារុណ**។ ជាការឆ្លើយតប មេធាវីបានថ្លែងថា គាត់គួរតែត្រូវអនុញ្ញាតឲ្យសួរដេញដោលសាក្សីពីកម្រិតនៃការចងចាំ (និងមិនមែនអ្វីដែលសាក្សីបានលើកឡើង ក្រោយពីសហព្រះរាជអាជ្ញា **លីសាក់** បានរំឭកការចងចាំទេ)។ ប្រធានអង្គជំនុំជម្រះបានសម្រេចតាមសំណើរបស់សហព្រះរាជអាជ្ញា ប៉ុន្តែពុំមែនដោយសារតាមអំណះអំណាងរបស់ពួកគេទេ គឺដោយសារតែសំណួររបស់មេធាវី **ប៉ៅ** ជាសំណួរច្រំដែល។

ហេតុផលនៅពីក្រោយការសម្រេច គឺហាក់មានការភ័ន្តច្រលំលើកម្មវត្ថុ ភាគីមានគោលបំណងសួរដេញដោលសាក្សីក្នុងគោលបំណងសួរផ្ទុញ ព្រោះតែសក្ខីកម្មរបស់គាត់ពុំស៊ីសង្វាក់គ្នា និងមិនត្រឹមត្រូវ ដែលពិតណាស់សំណួរមួយចំនួនត្រូវតែមានភាពច្រំដែល ដោយសារតែភាគីអាចប្រើប្រាស់វិធីសាស្ត្រនេះសម្រាប់ការសួរបញ្ជាក់ដំបូង។

នៅព្រឹកថ្ងៃបន្ទាប់ ថ្ងៃពុធ ទី១៣ មិថុនា មេធាវី **កាណាវ៉ាស** (មេធាវីការពារក្តីលោក **អៀង សារី**) បានស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះអំពីសេចក្តីសម្រេចលើករណីនេះ។ លោកមេធាវីបានសុំឲ្យមានការបញ្ជាក់ពីទិសដៅ "នៃរបៀបដែលភាគីអាចពន្លាតសមត្ថកិច្ចរបស់ខ្លួនក្នុងការប្រើប្រាស់សក្ខីកម្ម ក្នុងគោលបំណងធ្វើការបញ្ជាក់ ឬសួរផ្ទុញ"។ លោកមេធាវីមាន "មន្ទិលជាខ្លាំង" ក្នុងការបញ្ឈប់មិនឲ្យមានការចោទ សួរលើសក្ខីកម្មសាក្សីឡើងវិញ។ ជាការឆ្លើយតប ចៅក្រម **ស៊ីលវ៉ាំ ខាតវ៉ាយ** បានថ្លែងថា អង្គជំនុំជម្រះពុំយល់ពីតម្រូវការរបស់មេធាវី **កាណាវ៉ាស** និងសុំឲ្យមេធាវីដាក់សំណើជាលាយលក្ខណ៍អក្សរ តាមរយៈមន្ត្រីជាន់ខ្ពស់តុលាការ គឺជៀសវាការចំណាយពេលច្រើនចំពោះបញ្ហានេះ។ លោកស្រីចៅក្រមបានធានាថា អង្គជំនុំជម្រះនឹងធ្វើការឆ្លើយតបទៅនឹងសំណើ។

### គ. ការប្រើប្រាស់អត្ថបទបោះពុម្ពផ្សាយជាសាធារណៈជាភស្តុតាង

ក្នុងកំឡុងពេលមេធាវី **ប៉ៅ** សួរដេញដោលសាក្សី **សៅ សារុណ** នៅថ្ងៃអង្គារ មេធាវីបានយោងអត្ថបទបោះពុម្ពផ្សាយមួយរបស់លោក **ស្ទេវិន ហេតឌឺ** ស្តីអំពី "តួនាទីរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីថ្នាក់មូលដ្ឋាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ៖ តម្លាភាពរបស់ប្រជាជនកម្ពុជាក្នុងការទទួលបានទស្សនៈនៃក្នុងការប្រៀបធៀប"។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវីប្រើប្រាស់អត្ថបទនោះ ប៉ុន្តែក្រោយមក អង្គជំនុំជម្រះបានសុំឲ្យមានការបញ្ជាក់ពីប្រភពនៃឯកសារ។ មេធាវី **ប៉ៅ** បានពន្យល់ថា ឯកសារនោះមាននៅក្នុងប្រព័ន្ធទិន្នន័យអេឡិចត្រូនិចរបស់ **អ.វ.ត.ក** ប៉ុន្តែពុំបានដឹងថា ឯកសារនេះមាននៅក្នុងបញ្ជីរបស់ភាគី ហើយឯកសារនេះ គឺជាអត្ថបទសិក្សាស្រាវជ្រាវ ដែលអាចស្វែងរកបានដោយសេរីនៅក្នុងបណ្ណាល័យ ដូច្នេះ តុលាការគួរបានទទួលស្គាល់ឯកសារនេះ។

តំណាងសហព្រះរាជអាជ្ញា **លីសាក់** បានបញ្ជាក់ថា ឯកសារនេះពិតជាមាននៅក្នុងបញ្ជីរបស់ខ្លួន ប៉ុន្តែគាត់ពុំច្បាស់ថា តើអត្ថបទទាំងមូលត្រូវបានដាក់បញ្ចូល។ សហព្រះរាជអាជ្ញាបន្តថា ជាការចាំបាច់ណាស់ ដែលគ្រប់ភាគីទទួលព័ត៌មានពីឯកសារ ដូច្នេះពួកគេអាចពិនិត្យជាមុនបាន។

ប្រធានអង្គជំនុំជម្រះ **និល ណុន** បានណែនាំមេធាវី **ប៉ៅ** ឲ្យធ្វើការបញ្ជាក់ពីអត្តសញ្ញាណ និងឈ្មោះនៃឯកសារនីមួយៗ ដែលគាត់មានចេតនាក្នុងការប្រើប្រាស់ និងបញ្ជាក់ថាតើឯកសារនេះបានដាក់ចំពោះមុខអង្គជំនុំជម្រះ ៖

> *មេធាវី **ប៉ៅ** ! អង្គជំនុំជម្រះសូមរំឭកលោកម្តងទៀត ដូចដែលបានរំឭកជាច្រើនលើកហើយ លោកមេធាវីត្រូវអនុវត្តតាមគោលការណ៍ណែនាំ ក្នុងការស្នើសុំប្រើប្រាស់ឯកសារសួរតទល់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី។ ជាបឋម លោកមេធាវីត្រូវបង្ហាញ ថាតើឯកសារនោះត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះ ឬឯកសារមាននៅ ក្នុងបញ្ជីរបស់ភាគី។*

ចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** បានពន្យល់ថា ឯកសារមាននៅទីសារធារណៈ គឺមិនមានន័យថា ត្រូវតែទទួលស្គាល់ទេ។ ជាបន្ទាប់ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចថា រាល់ឯកសារត្រូវតែអនុវត្តន៍តាមវិធាន ៨៧.៣[15] និង ៨៧.៤[16]។

### ឃ. ការការពារសាក្សី និងតួនាទីរបស់មេធាវីប្រឹក្សា

នៅថ្ងៃប្រហស្បតិ៍ នៅពេលមេធាវី **អែនធ័រ វែកគែន** ដែលជាមេធាវីការពារក្តីលោក **ខៀវ សំផន** ចាប់ផ្តើមសួរដេញដោល សាក្សី **អឿន តាន** បានស្នើសុំការអនុញ្ញាតពិភាក្សាជាមួយមេធាវីប្រឹក្សាខ្លួន ព្រោះគាត់មានបញ្ហាពិបាកក្នុងការឆ្លើយសំណួរ ជាពិសេស ទាក់ទងនឹងភាពមិនស៊ីសង្វាក់នៃសក្ខីកម្មរបស់ខ្លួន។ មេធាវី **កាណាវ៉ាស** បានបដិសេធថា ករណីនេះពុំចាំបាច់ឲ្យសាក្សីពិភាក្សាជាមួយមេធាវីរបស់ខ្លួនទេ។ ភ្លាមៗនោះ អង្គជំនុំជម្រះបានសម្រេចតាមសេក្តីជំទាស់របស់មេធាវី **កាណាវ៉ាស** និងបានណែនាំសាក្សី **អឿន តាន** ថា តួនាទីមេធាវីប្រឹក្សា គឺត្រឹមតែផ្តល់យោបល់ នៅពេលមានសំណួរពាក់ព័ន្ធនឹងបញ្ហាប្រឈម ពាក់ព័ន្ធនឹងសក្ខីកម្មប្រឆាំងខ្លួនឯងប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺស្របតាមវិធាន ២៨.៩[17] ដែលចែងថា ការចូលរួមរបស់មេធាវីប្រឹក្សា គឺនៅពេលដែល "មានបញ្ហាណាមួយនៃការដាក់ពិរុទ្ធលើខ្លួនឯងកើតឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី"។

### ង. ការដាក់សំណើផ្ទាល់មាត់

នៅថ្ងៃអង្គារ មេធាវី **ប៉ៅ** បានស្នើសុំអង្គជំនុំជម្រះរយៈពេល ២នាទី ក្នុងការដាក់សំណើផ្ទាល់មាត់ និងធានាថា បញ្ហានេះពិតជាពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី **សៅ សារុណ** ទោះបីជាយ៉ាងណា អង្គជំនុំជម្រះពុំអនុញ្ញាតឲ្យឡើយ។ មេធាវី **ប៉ៅ** បានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះគួរបានឮពីបញ្ហាប្រឈមពាក់ព័ន្ធនឹងសាក្សី **សៅ សារុណ**។ ប្រធានអង្គជំនុំជម្រះថ្លែងថា សំណើនេះមិនអនុលោមតាមវិធាន ៩២ ដែលភាគីត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

នៅព្រឹកថ្ងៃពុធ បញ្ហានេះបានកើតជាថ្មីម្តងទៀត មេធាវី **កាណាវ៉ាស** បានស្នើសុំអង្គជំនុំជម្រះឲ្យធ្វើការបញ្ជាក់ពីសេចក្តីសម្រេចចំពោះការហាមប្រាមក្រុមមេធាវីការពារក្តីលោក **នួន ជា** លើការសួរបញ្ជាក់ ពីសក្ខីកម្មរបស់សាក្សី **សៅ សារុណ** ដែលសួរដេញដោលដោយសហព្រះរាជអាជ្ញា (សូមមើលផ្នែក III.ខ) ។ មេធាវី **ផេស្តមេន** បានសម្តែងការគាំទ្រចំពោះសំណើនេះ និងក៏បានស្នើសុំឲ្យមានការបញ្ជាក់ពីសំណើ របស់ខ្លួន ដែលធ្វើតាមរយៈអ៊ីម៉ែលផ្ញើជូនមន្ត្រីជាន់ខ្ពស់នៃតុលាការ កាលពីថ្ងៃទី២៤ មេសា ២០១២ អំពីបញ្ជីឯកសាររបស់ចៅក្រម។ អង្គជំនុំជម្រះបានបង្គាប់មេធាវីដោយថ្លែងថា ៖

> *...ប្រសិនបើលោកមេធាវីមានគោលបំណងដូចគ្នា ដូច្នេះ គួរតែលើកឡើងឲ្យចំបញ្ហាដែលពាក់ព័ន្ធ ទើបអង្គជំនុំជម្រះអាចយល់ដឹងបាន។ ប្រសិនបើលោកមេធាវីមានសំណើផ្សេង ដូច្នេះ អង្គជំនុំជម្រះសូមណែនាំថា លោកមេធាវីគួរធ្វើជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះនឹងសម្រេច នៅក្នុងពេលសមរម្យ។ ចំពោះបញ្ហានានាដែលមិនពាក់ព័ន្ធនឹងប្រធានបទស្តាប់សក្ខីកម្មសាក្សី TCW-488 ពុំអនុញ្ញាតឲ្យលើកឡើងទេ។*

មេធាវី **ផេស្តមិន** បានថ្លែងថា គាត់គ្រាន់តែសុំការបញ្ជាក់ ថាតើពេលណាអង្គជំនុំជម្រះនឹងធ្វើការសម្រេចលើសំណើនេះ។ អង្គជំនុំជម្រះបានថ្លែងថា សំណើទាំងនោះនឹងធ្វើការសម្រេចនៅក្នុងពេលសម ស្រប។

ផ្អែកតាមវិធាន ៨៥.១ ប្រធានអង្គជំនុំជម្រះដោយពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត "អាចបដិសេធនូវរាល់នីតិវិធី ដែលនាំឲ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"។ ***<u>ចំណាប់អារម្មណ៍</u> !*** នៅថ្ងៃពុធ អង្គជំនុំជម្រះណែនាំមេធាវី **ផេស្តមិន** ថា មានតែបញ្ហាពាក់ព័ន្ធនឹងសាក្សីដែលអាចអនុញ្ញាតឲ្យលើកឡើង ប៉ុន្តែអង្គជំនុំជម្រះពុំបានអនុញ្ញាតឲ្យមេធាវី **ប៉ៅ** ដាក់សំណើផ្ទាល់មាត់ (ជាបញ្ហាពាក់ព័ន្ធនឹងសាក្សីដែលគាត់កំពុងសួរដេញដោល)។ ដូច្នេះ សេចក្តីសម្រេច និងការណែនាំច្បាស់លាស់ អាចមានអត្ថប្រយោជន៍ដល់ដំណើរការនីតិវិធី។

### ច. បទសម្ភាសន៍នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ពុំមានជាខ្សែអាត់សម្លេង

នៅអំឡុងពេលមធាវី **វែកតែន** សួរដេញដោលសាក្សី **អឿន តាន** បានលេចចេញជាព័ត៌មានថា បទសម្ភាសន៍ចុះកាលបរិច្ឆេទ ថ្ងៃទី៩ តុលា ២០០៨ (D107/2R) ត្រូវបានធ្វើឡើងមុនមួយថ្ងៃ គឺថ្ងៃទី៨ តុលា ២០០៨ ប៉ុន្តែបទសម្ភាសន៍នេះ ពុំបានធ្វើជាលាយលក្ខណ៍អក្សរ ឬមានជាខ្សែអាត់សម្លេងឡើយ។ មេធាវី **កាណាវ៉ាស** បានលើកបញ្ហានេះសារជាថ្មី នៅពេលគាត់សួរដេញដោលសាក្សី **អឿន តាន**។ សាក្សីបញ្ជាក់ថា គាត់បានផ្តល់បទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៨ តុលា ២០០៨។ តំណាងសហព្រះរាជអាជ្ញា **អាប់ឌុលឡាក់** បានបញ្ជាក់ឲ្យមាន

ការត្រួតពិនិត្យលើប្រតិចារិកនៃបទសម្ភាសន៍នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ប៉ុន្តែអង្គជំនុំជម្រះពុំបានសម្រេចលើបញ្ហានេះទេ និងណែនាំឲ្យភាគីដាក់សំណើជាលាយលក្ខណ៍អក្សរ។

## ឆ. ការប្រើប្រាស់ឯកសារ ដែលពុំបានដាក់ចំពោះមុខអង្គជំនុំជម្រះ

នៅថ្ងៃអង្គារ មេធាវី **ប៉ៅ** បានស្នើសុំការអនុញ្ញាតដាក់បង្ហាញអត្ថបទមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា *ការបោសសម្អាតរបស់ខ្មែរក្រហមនៅខេត្តមណ្ឌលគីរី* ។ ប្រធានអង្គជំនុំជម្រះបានសាកសួរលោកមេធាវី ថាតើឯកសារនេះបានដាក់ចំពោះមុខអង្គជំនុំជម្រះ ផ្អែកតាមវិធានផ្ទៃក្នុងហើយឬនៅ។ ប្រធានអង្គជំនុំជម្រះបានរំឭកភាគីអំពីសេចក្តីណែនាំចុះថ្ងៃទី២៤ ឧសភា ២០១២ ដោយលើកឡើងថា រាល់ឯកសារត្រូវចាត់ថ្នាក់ជា “E3” ឬបានដាក់ចំពោះមុខអង្គជំនុំជម្រះយោងតាមវិធាន ៨៧។ មេធាវី **ប៉ៅ** បានធ្វើការកត់សម្គាល់ (ដើម្បីជាប្រតិចារិក) ថា ការធ្វើបែបនេះ គឺរំលោភសិទ្ធិកូនក្តីរបស់ខ្លួន ក្នុងការសួរតទល់សាក្សី។ ឯកសារនេះ “មាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា និងអាចស្វែងរកបាននៅក្នុងឯកសារ No. E109/4.19”។ តំណាងសហព្រះរាជអាជ្ញា **លីសាក់** បានបញ្ជាក់ថា ឯកសារនេះពិតជាមាននៅក្នុងឧបសម្ព័ន្ធរបស់ខ្លួន និងមិនជំទាស់ឡើយ ប្រសិនបើសំណួរមានជាប់ពាក់ព័ន្ធនឹងការយល់ដឹង និងមិនឲ្យសាក្សីធ្វើប្រមាណវិធី (ការប៉ាន់ស្មាន) ឡើយ។

ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះបានថ្លែងថា ពុំចាំបាច់ថា ឯកសារនោះមាននៅក្នុងឧបសម្ព័ន្ធ ភាគីត្រូវយល់ថា រាល់ឯកសារត្រូវចាត់ជាប្រភេទ “E3”។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវី **ប៉ៅ** ប្រើប្រាស់ឯកសារនោះក្នុងការសួរដេញដោលសាក្សី **សៅ សារុណ**។

## ឈ. ការប្រើប្រាស់ឯកសារដែលមិនមានការបកប្រែ

ការប្រើប្រាស់ឯកសារ អំពី “ការបោសសម្អាតនៅខេត្តមណ្ឌលគីរី” បានបណ្តាលឲ្យមានការជជែកដេញដោល ។ អង្គជំនុំជម្រះបានសាកសួរមេធាវី **ប៉ៅ** ថាតើឯកសារនោះមានជាភាសាខ្មែរ និងភាសាបារាំង? មេធាវី **ប៉ៅ** បានឆ្លើយថា ឯកសារនោះពុំមានបកប្រែជាភាសាដទៃទេ និងស្នើសុំថា ការបកប្រែជាភាសាខ្មែរ និងភាសាបារាំង អាចធ្វើនៅពេលគាត់អានឯកសារនេះ ព្រមទាំងលើកពីមូលហេតុមួយចំនួនទៀត [18] ប៉ុន្តែប្រធានអង្គជំនុំជម្រះបានបង្អាក់ ដោយថ្លែងថា មេធាវីពុំបានឆ្លើយតបនឹងសំណួរឡើយ។ មេធាវី **ប៉ៅ** បានឆ្លើយថា ឯកសារនេះមានតែជាភាសាអង់គ្លេសទេ និងសុំការអនុញ្ញាតប្រើប្រាស់ក្នុងការសួរដេញដោលសាក្សី។ អង្គជំនុំជម្រះបានអនុញ្ញាត និងណែនាំលោកមេធាវីឲ្យអានផ្នែកដែលខ្លួនមានបំណងចង់ដាក់បង្ហាញឲ្យខ្លីៗ ដើម្បីសម្រួលដល់ការបកប្រែ។

## ជ. ការប្រើប្រាស់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបញ្ជាក់ពីភាពជឿជាក់នៃ សាក្សី

នៅថ្ងៃប្រហស្បតិ៍ សហមេធាវីនាំមុខ **អេលីសាប៉ែត ស៊ីម៉ុនណូហ្វត** បានសួរដេញដោលសាក្សី **សៅ សារុណ** នៅពេលនោះមេធាវី **សុន អរុណ** បានធ្វើការជំទាស់ពីរបៀបនៃការសួរសំណួររបស់លោកស្រី ដោយផ្អែកលើមូលដ្ឋានថា សេចក្តីថ្លែងការណ៍របស់បុគ្គលទីពាមិនអាចប្រើប្រាស់ ក្នុងគោលបំណងសួរផ្ទុញសាក្សីទេ។ មេធាវី **កាណារ៉ាវ៉ាស** បានធ្វើការគាំទ្រលើការជំទាស់ និងបញ្ជាក់បន្ថែមថា សហមេធាវីនាំមុខ **ស៊ីម៉ុនណូហ្វត** កំពុងតែប្រើប្រាស់ឯកសាររបស់បុគ្គលដែលពុំបានធ្វើសម្បថ និងពុំមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ និងសម្តែងពីការព្រួយបារម្ភថា "ឯកសារនេះអាចផ្តល់តម្លៃ" ដោយអង្គជំនុំជម្រះ។

ជាការឆ្លើយតប មេធាវីនាំមុខ **ស៊ីម៉ុនណូហ្វត** បានលើកទឡ្ហីករណ៍ថា ការវាយតម្លៃ និងការផ្តល់ទម្ងន់នៃឯកសារ គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញាបានគាំទ្រដល់ការប្រើប្រាស់ឯកសារដោយមេធាវីនាំ មុខ ដោយឈរលើមូលដ្ឋានថា ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺបានបញ្ជាក់ពីព័ត៌មាន និងដំណើរអង្គហេតុយ៉ាងត្រឹមត្រូវ ដែលអាចទទួលខុសត្រូវចំពោះមុខច្បាប់ ដូច្នេះ "ដូចជាការធ្វើសម្បថ" ដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី (ជាង ៤000នាក់) ពួកគេនឹងមិនមកធ្វើសេក្តីថ្លែងការណ៍នៅចំពោះមុខតុលាការទាំងអស់នោះទេ។ មេធាវីនាំមុខជាតិ **ពេជ អង្គ** បានបញ្ជាក់ថា នៅក្នុងវិធាន ២៣ ពុំបានកំណត់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសម្បថទេ ដូច្នេះសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីគួរតែចាត់ទុកថាជាភស្តុតាង ៖

> *ខ្ញុំសូមថ្លែងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានកាតព្វកិច្ចក្នុងការធ្វើសម្បថ ដូចមាន ចែងនៅវិធាន ២៣ អំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី អាចជាផ្នែកមួយនៃភស្តុតាង ជួយដល់អង្គជំនុំជម្រះក្នុងការពិចារណាសម្រេចសេចក្តី។ ការពុំធ្វើសម្បថរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំចាត់ទុកជាកង្វល់ទេ។*

បន្ទាប់ពីស្តាប់ទឡ្ហីករណ៍របស់ភាគី ប្រធានអង្គជំនុំជម្រះ **និល ណុន** បានថ្លែងថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចលើកបញ្ហានេះនៅពេលក្រោយ។ នាពេលនោះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមេធាវី **ស៊ីម៉ុនណូហ្វត** អាចដកស្រង់ខ្លឹមសារពីសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយលក្ខខណ្ឌថា សេចក្តីថ្លែងការណ៍នេះមាន "តម្លៃតិចតួច" ប៉ុណ្ណោះ។

## IV. ការគ្រប់គ្រងសវនាការ

នាសប្តាហ៍នេះ អង្គជំនុំជម្រះបានដំណើរការសវនាការជាពិសេស ដោយផ្អែកលើស្ថានភាពសុខភាពរបស់សាក្សី **សៅ សារុណ** គឺបានកោះអញ្ជើញសាក្សីថ្មី (**ឃឹម ងន**) មកផ្តល់សក្ខីកម្ម នៅពេលសក្ខីកម្មរបស់សាក្សី **សៅ សា**

**រុណា** ពុំអាចបន្តទៅមុខបាន។ ករណីនេះ គឺជាកិច្ចប្រឹងប្រែង និងការយកចិត្តទុកដាក់របស់អង្គជំនុំជម្រះ ដោយពុំឲ្យខាតបង់ពេលវេលា។

**ក. វត្តមាន**

ដូចសប្តាហ៍មុនៗ ជនជាប់ចោទ **អៀង សារី** បន្តអវត្តមានពីបន្ទប់សវនាការ ដោយសារតែបញ្ហាសុខភាព ប៉ុន្តែបានតាមដានសវនាការពីចម្ងាយ។ ចំណែកឯជនជាប់ចោទ **នួន ជា** បានស្នើទៅធ្វើការតាមដានពីចម្ងាយនៅពេល រសៀល។ មានតែជនជាប់ចោទ **ខៀវ សំផន** ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍។

***ការចូលរួមរបស់សាធារណៈជន ៖*** នៅព្រឹកថ្ងៃច័ន្ទ អ្នកភូមិប្រហែលជា ៣០០នាក់ មកពីឃុំតំបែ ស្រុកតំបែ ខេត្តកំពង់ចាម រួមជាមួយនិស្សិតជាង ២០០នាក់ មកពីសកលវិទ្យាល័យភ្នំពេញ និងមហាវិទ្យាល័យខេមរៈ បានចូលរួមសវនាការ ។ នៅពេលរសៀល សិស្សានុសិស្សមកពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានវត្តមាននៅក្នុងសាលសវនាការ។

នៅថ្ងៃអង្គារ ប្រជាជនប្រមាណជា ៨០០នាក់ ៖ សិស្សានុសិស្សមកពីវិទ្យាល័យ **ហ៊ុន សែន ខ្លាគូន** ខេត្តបន្ទាយមានជ័យ ព្រមទាំង អ្នកភូមិមកពីឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ និងក្រុមនិស្សិត ១៩នាក់ មកពីសាលា **កាលេសតុន** រដ្ឋសោការ៉ូលីនា សហរដ្ឋអាមេរិក។

នៅថ្ងៃពុធ ប្រជាជនជាង ៥០០នាក់ មានវត្តមាននៅក្នុងសាលសវនាការ។ អ្នកភូមិជាង ៣០០នាក់ មកពីខេត្តស្វាយរៀង។ នៅពេលរសៀល និស្សិតជាង ១០០នាក់ មកពីមហាវិទ្យាល័យ **ស៊ី.យូ.អេស** បានចូលរួមសវនាការ។

នៅថ្ងៃប្រហស្បតិ៍ សិស្សជាង ៣០០នាក់ មកពីស្រុកក្រវាញ ខេត្តពោធិសាត់ ព្រមទាំង អ្នកភូមិជាង ១២០នាក់ មកពីស្រុកមុខកំពូល ខេត្តកណ្តាល ចូលរួមសវនាការនាពេលព្រឹក និងមានវត្តមានភ្ញៀវបរទេស មកពីរដ្ឋសភានៃ សហរដ្ឋអាមេរិកក៏បានចូលរួមផងដែរ។

## ខ. តារាងគ្រប់គ្រងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | ការសម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | ការសម្រាកពេលរសៀល | បិទសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| *ថ្ងៃច័ន្ទ ១១/ ០៦/ ១២* | ៩:០២ | ១០:៤០-១០:៥៤ | ១២:០៥-១៣:៣១ | ១៤:៣១-១៤:៥១ | ១៥:៥៣ | ៤ម៉ោង និង ៣០ នាទី |
| ថ្ងៃអង្គារ ១២/០៦/១២ | ៩:០៦ | ១០:៣៨-១១:០១ | ១២:១៣-១៣:៣២ | ១៤:៤៣-១៥:០២ | ១៦:០៣ | ៤ម៉ោង និង ៥៦ នាទី |
| ថ្ងៃពុធ ១៣/០៦/១២ | ៩:០៤ | ១០:៣៥-១០:៥៥ | ១២:០៤-១៣:៣១ | ១៤:៣៨-១៤:៥៨ | ១៦:០៤ | ៤ម៉ោង និង ៥៣នាទី |
| ថ្ងៃព្រហស្បតិ៍ ១៤/០៦/១២ | ៩:០៣ | ១០:៣២-១០:៤៧ | ១១:៥១ | - | - | ២ម៉ោង និង ៣៩នាទី |

ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ ៖ *៤ម៉ោង និង* ១៥ នាទី

ចំនួនម៉ោងសរុបក្នុងសប្តាហ៍នោះ ៖ *១៦* ម៉ោង និង ៥៨ នាទី

*ចំនួនសរុបនៃ ម៉ោង ថ្ងៃ និង សប្តាហ៍ ៖ ៣១៦ ម៉ោង និង ៥១ នាទី*

**៧៤ ថ្ងៃ និង ២២ សប្តាហ៍**

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC War Crimes Studies Center University of California, Berkeley

[*] AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Nora Fuchs, Ramu Nachiappan, Pavithra Prakash Nair, Noyel Ry, Kimsan Soy, Chayanich Thamparipattra, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

---

[1] International Co-Prosecutor Mr. Dale Lysak and Civil Party Co-Lawyer, Ms. Ty Srinna examined Sao Sarun on Monday morning. On Tuesday, Witness was questioned by Ty Srinna, CPLCL Ms. Elisabeth Simonneau-Fort, the Bench (through Judge Jean-Marc Lavergne), Nuon Chea's international counsel, Mr. Jasper Pauw, and Khieu Samphan's international counsel, Mr. Arthur Vercken.

[2] On Monday afternoon, International Prosecutor Vincent de Wilde D'Estmael concluded his examination of Khoem Ngorn and was followed by Civil Party Co-Lawyers Mr. Lor Chunthy and Mr. Barnabé Nekuie. International counsel for Nuon Chea, Mr. Michiel Pestman, thereafter examined the Witness Khoem Ngorn.

[3] Witness was questioned on Wednesday by Co-Prosecutor Mr. Veng Hout, international Co-Prosecutor Mr. Tarik Abdulhak, as well as national CPLCL Mr. Pich Ang and co-lawyer Mr. Kim Mengkhy. Thereafter, Judge Lavergne and President Nil Nonn questioned the Witness. On Thursday, Vercken, Mr. Son Arun (national counsel for Nuon Chea) and Michael Karnavas (international counsel for Ieng Sary), examined the Witness.

[4] Witness Sao Sarun was the secretary of Pech Chenda district from 1971 to 1978. He was Sector Secretary of Sector 105 for two months, until the Vietnamese invaded Cambodia. See CASE 002 KRT TRIAL MONITOR. Issue No. 24, Hearing on Evidence Week 19 (4-7 June 2012). 6.

[5] "K-11 was located approximately 1 kilometre Northeast of Phnom Kraol prison, and served as both a detention centre and as the military office." OCIJ. "Closing Order" (15 September 2010). D427 [hereinafter, **CLOSING ORDER**]. Paragraph 626.

[6] "K-17 consisted of a two storey building with wooden walls and a zinc roof and functioned as both the Office of the Secretary of Sector 105 and, briefly as a detention centre itself." CLOSING ORDER. Paragraph 626.

[7] "Phnom Kraol was located in Koh Nhek District, Sre Sangkum Subdistrict, Mondulkiri Province. Phnom Kraol was a Sector 105 Security Office containing Phnom Kraol Prison and related to the nearby Sector 105 Office K-11 and to the Sector 105 Secretary, headquartered Office K-17. Applying the CPK's system of identifying administrative boundaries, Phnom Kraol was located in Sector 105 also known as Mondulkiri Sector. The security centre already existed in 1975. Mondulkiri was under the control of the Northeast Zone until the end of 1976 when it became autonomous and thereafter reported directly to the CPK Centre." CLOSING ORDER. Paragraphs 625 and 626.

[8] "Successive secretaries of Sector 105 were based at K-17, including Ham alias Laing later alias Chhan (died under unclear circumstance in 1977), and in September 1978 [REDACTED**]**. After Laing's death, the sector was extensively purged, with some of those arrested being sent to Phnom Kraol. Deputy secretaries included Sau Kim An alias Mey (arrested on 8 December 1977) Cham, Phak and Lork." CLOSING ORDER. Paragraph 628.

[9] According to the Closing Order, Phnom Kraol was under military control. The sector military comprised two battalions, known as Battalion 1 and Battalion 2. Batallon 2 had a contingent in the Phnom Kraol, with Leng as the commander of battalion until his arrest in February 1978. CLOSING ORDER. Paragraph 630.

[10] The Closing Order indicates that "B-1" refers to the Ministry of Foreign Affairs. See Closing Order. Paras. 389 and 1005.

[11] However, while being questioned by Mr. Arthur Vercken the following day, Witness affirmed that Khieu Samphan was not in this group of persons who left for Phnom Penh.

[12] "K-7 was a messenger unit through which written communications addressed to *"Committee 870"* or "Office *870"* were routed before being directed to Pol Pot at K-1 as well as to the members of Committee 870 or its appropriate member depending on thematic responsibility. CLOSING ORDER. Paragraph 57.

[13] According to Witness Saloth Ban, Pang disappeared shortly before the Vietnamese arrived in January 1979. See CASE 002 KRT TRIAL MONITOR. Issue No. 20, Hearing on Evidence Week 15, (23-26 April 2012). 3.

[14] "A few months later, [Sao Sarun] was called to Phnom Penh with five other cadres for another meeting at the office located behind the Royal Palace with mostly military leaders from Sector 105 or Division 920. According to Sao Sarun, Pol Pot, Son Sen, Nuon Chea, and Khieu Samphan attended the meeting and discussed matters concerning "managing the forces," principles of self-sufficiency, and strengthening the border." CASE 002 KRT TRIAL MONITOR. Issue No. 25, Hearing on Evidence Week 19, (4-7 June 2012). 7.

[15] "The Chamber bases its decision on evidence from the case file provided it has been put before it by a party or if the Chamber itself has put it before the parties. Evidence from the case file is considered put before the Chamber or the parties if its content has been summarised, read out, or appropriately identified in court. The Chamber may reject a request for evidence where it finds that it is: I. irrelevant or repetitious; II. impossible to

obtain within a reasonable time; III. unsuitable to prove the facts it purports to prove; IV. not allowed under the law; or V. intended to prolong proceedings or is frivolous.” Extraordinary Chambers in the Courts of Cambodia Internal Rules (Rev. 8), as revised on 3 August 2011 [hereinafter, **INTERNAL RULES**]. Rule 87(3).

[16] “During the trial, either on its own initiative or at the request of a party, the Chamber may summon or hear any person as a witness or admit any new evidence which it deems conducive to ascertaining the truth. Any party making such request shall do so by a reasoned submission. The Chamber will determine the merit of any such request in accordance with the criteria set out in Rule 87(3) above. The requesting party must also satisfy the Chamber that the requested testimony or evidence was not available before the opening of the trial. INTERNAL RULES. Rule 87(4).

[17] “If an issue of self-incrimination arises in the course of the proceedings, the Co-Investigating Judges or the Chambers shall, unless the witness waives that right, suspend the taking of the testimony and provide the witness with a lawyer. Such waiver shall be recorded in accordance with Rule 25. INTERNAL RULES. Rule 28.9.

[18] Pauw gave the following reasons in support of his request: (i) the OCP does not object; (ii) it is relevant as it is related directly to the role of Mr. Sao Sarun; (iii) Civil Parties also relied on documents that were not translated into all languages; (iv) they would have a more “pleasant experience” if he were allowed to read the document and ask the questions based on this document and; (v) the document is not controversial in any way.